# មេរៀនសង្ខេប
# ស្តីពី
# ការចូលនិវត្តន៍

## ១. អំពីការចូលនិវត្តន៍ Retirement

គឺជាដំណាក់កាលចុងក្រោយនៃជីវិតការងាររបស់មន្ត្រីរាជការនៅក្នុងអាជីពរបស់ខ្លួន។ ការចូលនិវត្តន៍ចែកចេញជាៈ

- ការចូលនិវត្តន៍ដោយការដល់អាយុកំណត់ឲ្យចូលនិវត្តន៍
- ការចូលនិវត្តន៍មុនអាយុតាមការស្ម័គ្រចិត្ត
- ការដាក់ឲ្យចូលនិវត្តន៍ដោយបញ្ញត្តិ
- ការដាក់ឲ្យចូលនិវត្តន៍ដោយបាត់បង់សម្បទាវិជ្ជាជីវៈ។

### ១.១. ការចូលនិវត្តន៍ដោយការដល់អាយុកំណត់ឲ្យចូលនិវត្តន៍ Retirement by Ages

យោងតាមច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនិងលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌនីមួយៗ មន្ត្រីរាជការទាំងពីរភេទត្រូវដាក់ឲ្យចូលនិវត្តន៍នៅពេលដែលដល់អាយុចូលនិវត្តន៍ (៥៥.៥៨.៦០ឆ្នាំ) អាស្រ័យទៅតាមប្រភេទក្របខ័ណ្ឌ ប៉ុន្តែមន្ត្រីរាជការជាស្ត្រីប្រភេទក្របខ័ណ្ឌ (ខ.គ) អាចបន្តបំរើការងារដល់អាយុ ៦០ឆ្នាំ បើមិនចង់ចូលនិវត្តន៍តាមការកំណត់អាយុខាងលើនេះទេនោះ។មន្ត្រីរាជការចិតក្នុងឋានន្តរស័ក្តិទី១នៃក្របខ័ណ្ឌប្រភេទ "ក" (ក.១) សម្រេចឲ្យចូលនិវត្តដោយព្រះរាជក្រឹត្យ មន្ត្រីរាជការចិតក្នុងឋានន្តរស័ក្តិទី២នៃក្របខ័ណ្ឌប្រភេទ "ក" (ក.២) សម្រេចឲ្យចូលនិវត្តដោយអនុក្រឹត្យ មន្ត្រីរាជការចិតក្នុងឋានន្តរស័ក្តិទី៣នៃក្របខ័ណ្ឌប្រភេទ "ក" (ក.៣) សម្រេចឲ្យចូលនិវត្តដោយប្រកាសនិងមន្ត្រីរាជការក្របខ័ណ្ឌប្រភេទ ខ.គ សម្រេចឲ្យចូលនិវត្តន៍ដោយប្រកាស។

### ១.២. ការចូលនិវត្តន៍មុនអាយុតាមការស្ម័គ្រចិត្ត Voluntary Retirement

មន្ត្រីរាជការដែលមានអតីតភាពការងារ ៣០ឆ្នាំឡើងទៅ ហើយមានអាយុមិនទាន់ដល់អាយុកំណត់ឲ្យចូលនិវត្តន៍ អាចស្នើសុំចូលនិវត្តន៍បាន។ នៅពេលដែលមន្ត្រីរាជការនៃក្របខ័ណ្ឌណាមួយ បានបំរើការងារមានអតីតភាពគ្រប់ ៣០ឆ្នាំ ហើយ តែមិនទាន់ដល់អាយុត្រូវចូលនិវត្តន៍នោះ ក្រសួង ស្ថាប័ន មិនអាចចាប់បង្ខំគេឲ្យចូលនិវត្តន៍បានទេ។

### ១.៣. ការដាក់ឲ្យចូលនិវត្តន៍ដោយបញ្ញត្ត Automatic Retirement

គឺជាលិខិតបទដ្ឋានឯកត្តជនសម្រាប់ដាក់មន្ត្រីរាជការណាម្នាក់ឲ្យចូលនិវត្តន៍ដោយវិធានការវិន័យអនុវត្តបទបញ្ញត្តិក្នុងជំពូកទី៩នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល និង អនុក្រឹត្យស្តីពីនីតិវិធីអនុវត្តវិន័យចំពោះមន្ត្រីរាជការស៊ីវិល។ ការដាក់ឲ្យចូលនិវត្តន៍ដោយបញ្ញត្តិនៅពេលដែលមន្ត្រីរាជការប្រព្រឹត្តកំហុសធ្ងន់ក្នុងវិជ្ជាជីវៈ ដែលត្រូវទណ្ឌកម្មខាងវិន័យថ្នាក់ទី២ ចំណុច ឃ។

### ១.៤. ការដាក់ឲ្យចូលនិវត្តន៍ដោយបាត់បង់សម្បទាវិជ្ជាជីវៈ Placement on Disability Pension

ការដាក់ឲ្យចូលនិវត្តន៍នេះ ចំពោះមន្ត្រីរាជការទាំងពីរភេទដែលបាត់បង់សម្បទាវិជ្ជាជីវៈ ហើយមានអតីតភាពការងារចាប់ពី ២០ឆ្នាំ ទៅដល់ក្រោម ៣០ឆ្នាំ ហើយពុំគ្រប់អាយុចូលនិវត្តន៍។ ការកំណត់ថា មន្ត្រីរាជការណាម្នាក់បាត់បង់សម្បទាវិជ្ជាជីវៈ ត្រូវសម្រេចដោយគណៈកម្មការ តាមការកំណត់ក្នុងមាត្រា១៩នៃច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល។

ការបាត់បង់សម្បទាវិជ្ជាជីវៈ បែងចែកទៅតាមមូលហេតុដូចជាៈ

- បាត់បង់សម្បទាវិជ្ជាជីវៈដោយគ្រោះថ្នាក់ការងារ
- បាត់បង់សម្បទាវិជ្ជាជីវៈដោយគ្រោះថ្នាក់ការងារក្នុងពេលបំពេញបេសកកម្ម
- បាត់បង់សម្បទាវិជ្ជាជីវៈដោយសារជំងឺឬគ្រោះថ្នាក់ផ្សេងៗ។

**ក. បាត់បង់សម្បទាវិជ្ជាជីវៈដោយគ្រោះថ្នាក់ការងារ**

ត្រូវចាត់ទុកជាគ្រោះថ្នាក់ការងារ គឺគ្រោះថ្នាក់ដែលកើតឡើងដោយធ្វើការឬក្នុងពេលធ្វើការជូនក្រសួង ស្ថាប័ន ទោះមានហេតុផលយ៉ាងណាក៏ដោយ ឬមានកំហុសមកពីអ្នករាជការ ឬគ្មានក៏ដោយ ហើយបណ្តាលឲ្យបាត់បង់សម្បទាវិជ្ជាជីវៈការងារទាំងស្រុងនិងអចិន្ត្រៃយ៍។

ឧ.ទាៈ

- គ្រោះថ្នាក់កើតឡើងក្នុងពេលម៉ោងធ្វើការទាំងក្នុងនិងក្រៅក្រសួង ស្ថាប័ន ដែលអ្នករាជការបានបំពេញភារកិច្ចរបស់ខ្លួន។
- គ្រោះថ្នាក់ក្នុងរយៈពេលធ្វើការនិងនៅពេលមុនឬក្រោយពេលធ្វើការ ដែលអ្នករាជការរៀបចំសំភារៈពលកម្ម ឬម៉ាស៊ីន។
- គ្រោះថ្នាក់ក្នុងការបំពេញសេចក្តីត្រូវការផ្ទាល់ខ្លួនក្នុងរយៈពេលធ្វើការ ដូចជា ពេលសម្រាកហូបចុកនិងពេលបំបៅកូនកណ្តាលវេន ពេលសំអាតខ្លួននៅពេលក្រោយធ្វើការ។
- គ្រោះថ្នាក់ដែលបណ្តាលមកពីកត្តាដែលមានគ្រោះថ្នាក់មានជាតិពុលដោយមិនដឹងខ្លួនជាមុនក្នុងក្រសួង ស្ថាប័ននិងក្នុងផលិតកម្ម ហើយបណ្តាលឲ្យមានរបួសពុលសន្លប់ដល់អ្នករាជការ ហើយធ្វើឲ្យបាត់បង់សម្បទាវិជ្ជាជីវៈជាស្ថាពរនូវសមត្ថភាពការងារ។
- គ្រោះថ្នាក់ដែលធ្លាក់លើអ្នករាជការ ក្នុងពេលដែលអ្នកទាំងនោះធ្វើដំណើរពីលំនៅដ្ឋានរបស់ខ្លួនឆ្ពោះត្រង់ទៅកន្លែងធ្វើការ ឬវិលមកវិញដោយគ្មានឈប់ ឬដោយគ្មានវៀងទៅទីណាជាប្រយោជន៍ផ្ទាល់ខ្លួន។

**ខ. បាត់បង់សម្បទាវិជ្ជាជីវៈដោយគ្រោះថ្នាក់ការងារក្នុងពេលបំពេញបេសកកម្ម**

- គ្រោះថ្នាក់នៅពេលអ្នករាជការបញ្ចេញនូវវីរៈភាពក្នុងការបំពេញបេសកកម្មដែលក្រសួង ស្ថាប័ន អង្គភាពប្រគល់ឲ្យ ហើយបានលះបង់ជីវិតរបស់ខ្លួន។
- គ្រោះថ្នាក់ដែលកើតឡើងក្នុងពេលអ្នករាជការការពារទ្រព្យសម្បត្តិរដ្ឋឬសាធារណៈ ដូចជា ភ្លើងឆេះផ្ទះ ទឹកជំនន់។ល។

**គ. បាត់បង់សម្បទាវិជ្ជាជីវៈដោយសារជំងឺឬគ្រោះថ្នាក់ផ្សេងៗ**

ការដាក់ឲ្យចូលនិវត្តន៍ដោយសារការបាត់បង់សម្បទាវិជ្ជាជីវៈដោយសារមន្ត្រីរាជការមានជំងឺ ឬដោយសារគ្រោះថ្នាក់ផ្សេងៗក្រៅពីករណីគ្រោះថ្នាក់ខាងលើ។

**២. អំពីប្រាក់សោធននិវត្តន៍** Retirement Pension

ប្រាក់សោធននិវត្តន៍របស់មន្ត្រីរាជការប្រែប្រួលទៅតាមស្ថានភាពចូលនិវត្តន៍របស់មន្ត្រីម្នាក់ៗ ដែលក្នុងនោះមាននិវត្តន៍ជនខ្លះទទួលបាន ៨០%នៃបៀវត្សមូលដ្ឋាន ខ្លះទទួលបាន ៦០%នៃបៀវត្សមូលដ្ឋានជាដើម។

ប្រាក់សោធននិវត្តន៍រួមមាន:

- ប្រាក់សោធននិវត្តន៍អតីតភាព Seniority Retirement Pension
- ប្រាក់សោធននិវត្តន៍សមាមាត្រឬប្រាក់សោធនអប្បបរមា Proportional Retirement Pension or Minimum Retirement Pension
- ប្រាក់ឧបត្ថម្ភតែមួយលើក Lump Sum
- ប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈអតិបរមា Maximum Professional Unfitness Pension
- ប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈអប្បបរមាឬសមាមាត្រ Minimum Professional Unfitness Pension
- ប្រាក់ឧបត្ថម្ភបាត់បង់សម្បទាវិជ្ជាជីវៈតែមួយលើក Minimum Professional Unfitness pension

### ២.១. ប្រាក់សោធននិវត្តន៍អតីតភាព Seniority Retirement Pension

ផ្តល់ជូនមន្ត្រីរាជការដែលដល់អាយុចូលនិវត្តន៍តាមការកំណត់ + មានអតីតភាពបំរើការងារយ៉ាងតិច ៣០ឆ្នាំ ឬមន្ត្រីរាជការដែលស្នើសុំចូលនិវត្តន៍មុនដល់អាយុចូលនិវត្តន៍តាមការកំណត់ ប៉ុន្តែមានអតីតភាពបំរើការងារយ៉ាងតិច ៣០ឆ្នាំ។

**ប្រាក់សោធននិវត្តន៍អតីតភាព** = ៨០%នៃបៀវត្សមូលដ្ឋានចុងក្រោយ + ប្រាក់វិភាជន៍គ្រួសារ + ប្រាក់ឧបត្ថម្ភផ្សេងទៀត(បើមាន)។

**ប្រាក់សោធននិវត្តន៍អតីតភាព** ផ្តល់ជូននិវត្តន៍ជនប្រចាំខែរហូតដល់ពេលនិវត្តន៍ជននោះទទួលមរណៈភាព បើកនៅបេឡាជាតិសន្តិសុខសង្គមមន្ត្រីរាជការស៊ីវិល។

### ២.២. ប្រាក់សោធននិវត្តន៍សមាមាត្រឬប្រាក់សោធនអប្បបរមា Proportional Retirement Pension or Minimum Retirement Pension

ផ្តល់ជូនមន្ត្រីរាជការដែលដល់អាយុចូលនិវត្តន៍តាមការកំណត់ + មានអតីតភាពបំរើការងារចាប់ពី ២០ឆ្នាំ ដល់ក្រោម ៣០ឆ្នាំ។

**ប្រាក់សោធននិវត្តន៍សមាមាត្រឬប្រាក់សោធនអប្បបរមា** = ៦០%នៃបៀវត្សមូលដ្ឋានចុងក្រោយ + (២% X ចំនួនឆ្នាំដែលលើសពី ២០ឆ្នាំ) + ប្រាក់វិភាជន៍គ្រួសារ + ប្រាក់ឧបត្ថម្ភផ្សេងទៀត(បើមាន)។

**ប្រាក់សោធននិវត្តន៍សមាមាត្រឬប្រាក់សោធនអប្បបរមា** ផ្តល់ជូននិវត្តន៍ជនប្រចាំខែរហូតដល់ពេលនិវត្តន៍ជននោះទទួលមរណៈភាព បើកនៅបេឡាជាតិសន្តិសុខសង្គមមន្ត្រីរាជការស៊ីវិល។

### ២.៣. ប្រាក់ឧបត្ថម្ភតែមួយលើក Lump Sum

ផ្តល់ជូនមន្ត្រីរាជការដែលមានអាយុគ្រប់ចូលនិវត្តន៍ប៉ុន្តែមានអតីតភាពបំរើការងារតិចជាង២០ឆ្នាំ ឬផ្តល់ជូនមន្ត្រីរាជការដែលស្នើសុំឈប់ពីការងារដោយស្ម័គ្រចិត្ត + ប្រធានក្រសួង ស្ថាប័នយល់ព្រមតាមសំណើ។

ប្រាក់ឧបត្ថម្ភតែមួយលើកនេះ ទាបបំផុតស្មើនឹងបៀវត្សមូលដ្ឋានចុងក្រោយ X ៤ និងខ្ពស់បំផុតស្មើនឹងបៀវត្សមូលដ្ឋានចុងក្រោយ X ១០។

**បៀវត្សមូលដ្ឋានចុងក្រោយ X ៤ ≤ ប្រាក់ឧបត្ថម្ភមួយលើក≤ បៀវត្សមូលដ្ឋានចុងក្រោយ X ១០**

### ២.៤. ប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវ:អតិបរមា Maximum Professional Unfitness Pension

ផ្តល់ជូនមន្ត្រីរាជការដែលបាត់បង់សម្បទាវិជ្ជាជីវ: (ដោយគ្រោះថ្នាក់ការងារឬក្នុងពេលបំពេញបេសកកម្ម) + មានអតីតភាពបំរើការងារចាប់ពី ២០ឆ្នាំ ដល់ក្រោម ៣០ឆ្នាំ + ពុំគ្រប់អាយុចូលនិវត្តន៍។

ប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវ:អតិបរមា = ៦៥%នៃបៀវត្សមូលដ្ឋានចុងក្រោយ + ប្រាក់វិភាជន៍គ្រួសារ + ប្រាក់ឧបត្ថម្ភផ្សេងទៀត(បើមាន)។

### ២.៥. ប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវ:អប្បបរមាឬសមាមាត្រ Minimum Professional Unfitness Pension

ផ្តល់ជូនមន្ត្រីរាជការដែលបាត់បង់សម្បទាវិជ្ជាជីវ: (ដោយជម្ងឺឬគ្រោះថ្នាក់ផ្សេងៗ) + មានអតីតភាពបំរើការងារចាប់ពី ២០ឆ្នាំ ដល់ក្រោម ៣០ឆ្នាំ + ពុំគ្រប់អាយុចូលនិវត្តន៍។

**ប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវ:អប្បបរមាឬសមាមាត្រ** = ៥០%នៃបៀវត្សមូលដ្ឋានចុងក្រោយ + (១.៥%X ចំនួនឆ្នាំដែលលើសពី ២០ឆ្នាំ) + ប្រាក់វិភាជន៍គ្រួសារ + ប្រាក់ឧបត្ថម្ភផ្សេងទៀត(បើមាន)។

### ២.៦. ប្រាក់ឧបត្ថម្ភបាត់បង់សម្បទាវិជ្ជាជីវ:តែមួយលើក Minimum Professional Unfitness pension

ផ្តល់ជូនមន្ត្រីរាជការដែលបាត់បង់សម្បទាវិជ្ជាជីវ: មានអតីតភាពបំរើការងារតិចជាង ២០ឆ្នាំ ក្រសួង ស្ថាប័នតម្រូវឲ្យចូលបាត់បង់សម្បទាវិជ្ជាជីវ:។ យោងលិខិតលេខ១៤៣ ស.ជ.ណ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៩ **ប្រាក់ឧបត្ថម្ភបាត់បង់សម្បទាវិជ្ជាជីវ:តែមួយលើក** = បៀវត្សមូលដ្ឋានចុងក្រោយ X ៧។

មន្ត្រីរាជការដែលចូលបាត់បង់សម្បទាវិជ្ជាជីវ: នៅពេលទទួលមរណ:ភាពគ្រួសារនៃសពទទួលបានប្រាក់ឧបត្ថម្ភដូចនិវត្តន៍ជនដែរ ស្មើនឹងប្រាក់សោធនប្រចាំខែ X ១២ខែ។

## ៣. ភារកិច្ចនិងសមត្ថកិច្ចនៃការគ្រប់គ្រងបើកប្រាក់សោធននិវត្តន៍និងសោធនបាត់បង់សម្បទាវិជ្ជាជីវ:

បច្ចុប្បន្ននេះ បេឡាជាតិសន្តិសុខសង្គមមន្ត្រីរាជការស៊ីវិល កំពុងដំណើរការបើកផ្តល់តាវកាលិកជូនមន្ត្រីរាជការស៊ីវិល និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវ: និងអ្នកនៅក្នុងបន្ទុក តាមគោលការណ៍អភិបាលកិច្ចល្អ មានតម្លាភាព ប្រសិទ្ធិភាព និងមានការទទួលខុសត្រូវខ្ពស់។

**សូមអរគុណ!**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

❖◆❖

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៩ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការអនុវត្តរបបសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈ ចំពោះមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស-រកត ១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខនស-រកត១០៩៤-៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ ០២ នស៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦ នស៩៤ ចុះថ្ងៃទី ៣០ ខែ តុលាឆ្នាំ១៩៩៤ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល
- បានឃើញព្រះរាជក្រម លេខនសរកម០១៩៦/១៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន
- បានឃើញព្រះរាជក្រឹត្យលេខជស/រកត០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- តាមសេចក្តីស្នើសុំពីរដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន
- បានការយល់ព្រមពីគណៈរដ្ឋមន្ត្រី នាសម័យប្រជុំថ្ងៃទី ២១ ខែ សីហា ឆ្នាំ ១៩៩៧

# សំរេច
# ជំពូកទី ១
# របបសោធននិវត្តន៍

មាត្រា១: អ្នករាជការទាំងពីរភេទ ត្រូវបានទទួលរបបសោធននិវត្តន៍ ប្រចាំខែបាន លុះត្រាតែបានបំពេញតាមល័ក្ខខ័ណ្ឌ ដូចមានចែងក្នុងមាត្រា៥៤ និង មាត្រា៥៥ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ។

មាត្រា២: អ្នករាជការទាំងពីរភេទ ត្រូវបានទទួលប្រាក់សោធននិវត្តន៍អតីតភាព ស្មើនឹង៨០ភាគរយនៃបៀវត្សសុទ្ធសាធ របស់សាមីខ្លួន លុះត្រាតែបានបំពេញការងារយ៉ាងតិច៣០ ឆ្នាំ ។

ប្រាក់សោធនអតីតភាពនេះ ត្រូវបានអនុវត្តតាមករណីដូចខាងក្រោម ៖

-អ្នករាជការមានអាយុ ៥៥ ឆ្នាំយ៉ាងតិច និង មានអតីតភាពការងារ ៣០ ឆ្នាំយ៉ាងតិច ។

-អ្នករាជការដែលមានអតីតភាព ការងារ៣០ឆ្នាំឡើងទៅ ហើយបានស្ម័គ្រចិត្តសុំចូលនិវត្តន៍ មុនអាយុ៥៥ឆ្នាំ។

មាត្រា៣: ចំពោះអ្នករាជការ ដែលបានបំពេញល័ក្ខខ័ណ្ឌចូលនិវត្តន៍ ដូចមានចែងក្នុងមាត្រា១ខាងលើ ហើយមានអតីតភាពការងារ២០ឆ្នាំយ៉ាងតិច ត្រូវបានទទួលប្រាក់សោធននិវត្តន៍ អប្បបរិមាស្មើនឹង៦០ភាគរយនៃបៀវត្សសុទ្ធសាធរបស់សាមីខ្លួន។អ្នករាជការដែលបានបំពេញការងារ លើសពី២០ឆ្នាំឡើង ត្រូវបានទទួលប្រាក់សមាមាត្របន្ថែម២ភាគរយ ក្នុង១ឆ្នាំលើបៀវត្សសុទ្ធសាធ របស់សាមីខ្លួន។ប្រាក់សោធននិវត្តន៍សមាមាត្រនេះ ត្រូវបានគិតតាមករណីពីរយ៉ាងដូចខាងក្រោម ៖

១-មិនត្រូវខ្ពស់ជាងប្រាក់សោធននិវត្តន៍ អតីតភាព ៨០ ភាគរយឡើយ ។

២-មិនត្រូវទាបជាងប្រាក់បៀវត្ស អប្បបរិមាសុទ្ធសាធប្រចាំខែ នៃតារាងកាំប្រាក់របស់សាមីខ្លួនឡើយ។

មាត្រា៤: ប្រាក់សោធននិវត្តន៍ ប្រចាំខែរបស់និវត្តជនម្នាក់ៗ ត្រូវបានគិតបន្ថែមប្រាក់តំបន់នៅតាមតំបន់ ដែលសាមីខ្លួនរស់នៅ ប្រាក់ប៉ះពាល់សុខភាព ចំពោះអ្នករាជការដែលធ្វើការងារធ្ងន់ ការងារលំបាក ការងារប៉ះពាល់សុខភាព ដូចពេលកំពុងបំរើការងារមុនពេលចូលនិវត្តន៍ ប្រាក់ឧបត្ថម្ភប្រពន្ធ កូនក្រោមអាយុ១៥ឆ្នាំនិងចាប់ពីអាយុ១៥ឆ្នាំឡើងទៅត្រូវមានលិខិតបញ្ជាក់ការសិក្សាពីស្ថាប័នមានសមត្ថកិច្ច និង ប្រាក់ឧបត្ថម្ភផ្សេងៗទៀតដែលរដ្ឋបានកំណត់ ។

មាត្រា៥: អ្នករាជការដែលត្រូវបានក្រសួង ស្ថាប័នប្រកាសអោយចូលនិវត្តន៍ ត្រូវបានទទួលប្រាក់ឧបត្ថម្ភ ម្តងគត់ ស្មើនឹងបៀវត្សសរុបប្រចាំខែ ចំនួន ៨ ខែ ។

**មាត្រា៦:** អ្នករាជការដែលមានអាយុគ្រប់ចូលនិវត្តន៍ ប៉ុន្តែមានអតីតភាពការងារ តិចជាង២០ឆ្នាំ មិនត្រូវផ្តល់ប្រាក់សោធននិវត្តន៍ឡើយ ។ ក្នុងករណីនេះ រដ្ឋផ្តល់ប្រាក់ឧបត្ថម្ភជាប្រាក់សោធននិវត្តន៍ ដែលបានកាត់ទុកនិងប្រាក់ឧបត្ថម្ភផ្សេងៗទៀត តែមួយលើក ។ប៉ុន្តែនៅពេលមិនទាន់បានបង្កើត បេឡាសោធននិវត្តន៍ និងបាត់បង់សម្បទាវិជ្ជាជីវៈ រដ្ឋត្រូវចំណាយប្រាក់ឧបត្ថម្ភនេះ ដោយគិតតាមចំនួនឆ្នាំ ដែលសាមីខ្លួនបានបំរើការងាររដ្ឋរហូតដល់ថ្ងៃដែលត្រូវបញ្ឈប់ពីការងារ។ប្រាក់ឧបត្ថម្ភនេះ ត្រូវគិតតាមចំនួនឆ្នាំដែលបានបំរើការងាររដ្ឋ ដោយកំណត់ទាបបំផុតស្មើនឹង បៀវត្សសរុបប្រចាំខែ របស់សាមីខ្លួនគុណនឹង៤ ហើយខ្ពស់បំផុតស្មើនឹង បៀវត្សសរុបប្រចាំខែ របស់សាមីខ្លួនគុណនឹង១០ ។

**មាត្រា៧:** ចំពោះអ្នករាជការ ដែលដល់អាយុចូលនិវត្តន៍ និង មានអតីតភាពការងារគ្រប់ ៣០ ឆ្នាំ ដូចមានចែងក្នុងមាត្រា៥៦ នៃច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ហើយត្រូវបានរដ្ឋអនុញ្ញាតអោយបន្តការងារបន្ថែមទៀត មិនត្រូវកាត់ទុកប្រាក់សោធននិវត្តន៍ទៀតឡើយ ។

**មាត្រា៨:** របៀបគិតអតីតភាពការងារ របស់អ្នករាជការ ត្រូវបានកំណត់ដូចខាងក្រោម ៖

រយៈពេលបំរើការងាររួម នៃអ្នករាជការស៊ីវិល គឺជារយៈពេលបំរើការងាររដ្ឋគ្រប់របបសង្គម ។ ដោយឡែក ចំពោះអ្នករាជការដែលធ្លាប់បានបំរើការងាររដ្ឋ មុនឆ្នាំ១៩៧៥ ហើយពុំបានបំរើការងារក្នុងរបបប៉ុលពត ក៏ត្រូវបានគិតបន្ថែមរយៈពេលបំរើការងារ ៣ឆ្នាំ ៨ខែ និង ២០ថ្ងៃថែមទៀតដែរ ។

រយៈពេលបំរើការងារ នៃអ្នករាជការស៊ីវិលរួមមាន ៖

- រយៈពេលបំរើការងារ ក្នុងក្របខ័ណ្ឌពេញសិទ្ធិ នៅតាមក្រសួងស្ថាប័ននានារបស់រដ្ឋ
- រយៈពេលធ្វើកម្មសិក្សា ឬ បណ្តុះបណ្តាលមុខវិជ្ជាជីវៈ ក្នុង ឬ ក្រៅ ប្រទេសរបស់អ្នករាជការក្នុងក្របខ័ណ្ឌរដ្ឋ
- រយៈពេលដែលរដ្ឋចាត់អោយទៅបំរើការងារ នៅក្រៅប្រទេស
- រយៈពេលឃាត់ ឬ ឃុំខ្លួន តែក្រោយមករកពុំឃើញ
- រយៈពេលបំរើការងារ ក្នុងកងយោធពលខេមរភូមិន្ទ និង នគរបាលជាតិ
- រយៈពេលធ្វើកម្មសិក្សា មុនបញ្ចូលក្របខ័ណ្ឌពេញសិទ្ធិ

មិនត្រូវចាត់ទុកជារយៈពេលបំរើការងារ គឺរយៈពេលត្រូវបានអនុញ្ញាតអោយឈប់ទំនេរ ដោយមិនទទួលបៀវត្ស។

**មាត្រា៩:** អ្នករាជការស៊ីវិលទាំងពីរភេទ ដែលមានអាយុលើសពី៥៥ឆ្នាំ អាចបន្តការងារបានលុះត្រាតែបានបំពេញលក្ខខ័ណ្ឌ ក្នុងមាត្រា៦៣នៃច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល និងអនុក្រឹត្យលេខ៨០អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ១៩៩៦ ស្តីពីការកំណត់លក្ខណៈវិនិច្ឆ័យមន្ត្រីរាជការស៊ីវិល ដែលស្នើសុំពន្យារពេលចូលនិវត្តន៍ ។

មាត្រា១០: នៅពេលនិវត្តជនទទួលមរណៈភាព គ្រួសារនៃសពត្រូវបានរដ្ឋ ផ្តល់ប្រាក់ឧបត្ថម្ភមួយលើក ចំនួន ១២ខែ លើប្រាក់សោធននិវត្តន៍សរុប ប្រចាំខែរបស់សាមីខ្លួន ដើម្បីធ្វើបុណ្យតាមប្រពៃណី ។ ដោយឡែក ចំពោះសហព័ន្ធនៃសពត្រូវបានបន្តទទួល ប្រាក់ឧបត្ថម្ភប្រចាំខែ រហូតដល់ពេលគាត់ស្លាប់ ឬ មានគ្រួសារថ្មី ។ កូនកំព្រានៃសព ត្រូវបានទទួលប្រាក់ឧបត្ថម្ភប្រចាំខែ ដូចកូនកំព្រានៃសពមន្ត្រីរាជការ រហូតដល់អាយុ១៥ឆ្នាំ និងចាប់ពីអាយុ១៥ឆ្នាំឡើងទៅ ត្រូវមានលិខិតបញ្ជាក់ការសិក្សា ពីស្ថាប័នមានសមត្ថកិច្ច ។

## ជំពូកទី ២
## របបសោធនបាត់បង់សម្បទាវិជ្ជាជីវៈ

មាត្រា១១: អ្នករាជការទាំងពីរភេទ ដែលបាត់បង់សម្បទាវិជ្ជាជីវៈ ហើយមានអតីតភាពការងារ ចាប់ពី២០ឆ្នាំទៅ ដល់ក្រោម៣០ឆ្នាំ ហើយពុំគ្រប់អាយុចូលនិវត្តន៍ មានសិទ្ធិទទួលប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈ ដូចមាន ចែងក្នុងមាត្រា១៩ នៃច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល។ក្នុងករណីមិនគ្រប់លក្ខខ័ណ្ឌនេះ ត្រូវបានបញ្ឈប់ ពីការងារនៅពេលណាក៏បាន ហើយត្រូវបានទទួលប្រាក់ឧបត្ថម្ភ និង ប្រាក់កាត់ទុកតែម្តងគត់ ដូចអ្នករាជការពុំ គ្រប់លក្ខខ័ណ្ឌចូលនិវត្តន៍ដែរ ។

ប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈ អតិបរិមាត្រូវបានកំណត់៦៥ភាគរយ នៃបៀវត្សសុទ្ធសាធ ប្រាក់សោធននេះ ត្រូវអនុវត្តចំពោះអ្នករាជការណា ដែលបាត់បង់សម្បទាវិជ្ជាជីវៈ ដោយគ្រោះថ្នាក់ការងារនិង បំពេញបេសកកម្ម ។

ប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈ អប្បបរិមាត្រូវបានកំណត់៥០ភាគរយ នៃបៀវត្សសុទ្ធសាធ ប្រាក់សោធននេះ ត្រូវអនុវត្តចំពោះអ្នករាជការណា ដែលបាត់បង់សម្បទាវិជ្ជាជីវៈ ដោយជំងឺ ឬ គ្រោះថ្នាក់ ផ្សេងៗ ។ ចំពោះអ្នករាជការដែលមានអតីតភាពការងារ លើសពី២០ឆ្នាំឡើងទៅ ត្រូវបានទទួលប្រាក់សោធន បាត់បង់សម្បទាវិជ្ជាជីវៈអប្បបរិមា និងត្រូវបានទទួលប្រាក់សមាមាត្របន្ថែម១,៥ភាគរយ ក្នុងមួយឆ្នាំលើ បៀវត្សសុទ្ធសាធ របស់សាមីខ្លួន។ ប៉ុន្តែប្រាក់សោធនសមាមាត្រនេះ មិនត្រូវលើសប្រាក់សោធនបាត់បង់ សម្បទាវិជ្ជាជីវៈ អតិបរិមា ឬ មិនត្រូវទាបជាង៩០ភាគរយ នៃប្រាក់បៀវត្សអប្បបរិមាសុទ្ធសាធ នៃតារាងកាំ ប្រាក់របស់សាមីខ្លួនឡើយ ។

ការកំណត់ថាបាត់បង់សម្បទាវិជ្ជាជីវៈ នៃអ្នករាជការស៊ីវិល ត្រូវសំរេចដោយគណៈកម្មការមួយ ដូចមានចែងក្នុងមាត្រា១៩ នៃច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ។

**មាត្រា១២:** អ្នករាជការបាត់បង់សម្បទាវិជ្ជាជីវៈម្នាក់ៗ ត្រូវបានទទួលប្រាក់ឧបត្ថម្ភ ប្រាក់តំបន់ ប្រាក់ប៉ះពាល់សុខភាព ប្រាក់ឧបត្ថម្ភប្រពន្ធ កូន និង ប្រាក់ឧបត្ថម្ភផ្សេងៗទៀត ដូចជានិវត្តជនដែរ ។

**មាត្រា១៣:** អ្នករាជការដែលបាត់បង់សម្បទាវិជ្ជាជីវៈ ត្រូវបានអនុវត្តរបៀបគិតរយៈពេលបំពេញការងារ ដូចជានិវត្តជនដែរ ។

**មាត្រា១៤:** អ្នករាជការដែលក្រសួង ស្ថាប័ន តម្រូវអោយចូលបាត់បង់សម្បទាវិជ្ជាជីវៈ ត្រូវបានទទួលប្រាក់ឧបត្ថម្ភម្តងគត់ ស្មើនឹងបៀវត្សសរុបប្រចាំខែចំនួន ៧ ខែ ។

**មាត្រា១៥:** អ្នករាជការដែលបាត់បង់សម្បទាវិជ្ជាជីវៈ នៅពេលទទួលមរណៈភាព គ្រួសារនៃសពត្រូវបានវដ្តឧបត្ថម្ភប្រាក់ ដូចជានិវត្តជនដែរ ។

## ជំពូក ទី ៣
## ភារកិច្ច និង សមត្ថកិច្ច នៃការគ្រប់គ្រង
## បើកប្រាក់សោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈ

**មាត្រា១៦:** ជារៀងរាល់ឆ្នាំក្រសួង ស្ថាប័ននីមួយៗ ត្រូវលើកគំរោងផែនការស្ថិតិ និង ថវិកា សំរាប់អ្នករាជការក្រោមឱវាទ ដែលគ្រប់ល័ក្ខខ័ណ្ឌចូលនិវត្តន៍ និងចូលបាត់បង់សម្បទាវិជ្ជាជីវៈ ជូនក្រសួងសង្គមកិច្ចការងារនិងអតីតយុទ្ធជន និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីបំរុងថវិកាសំរាប់បើកផ្តល់ជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ។

ក្រសួង ស្ថាប័ននិមួយៗមានភារកិច្ច លើកគំរោងផែនការថវិកា និង បើកប្រាក់ឧបត្ថម្ភលើកដំបូង ជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ។ ការបើកប្រាក់ឧបត្ថម្ភលើកដំបូងនេះ ត្រូវស្នើទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

ការគ្រប់គ្រង និង ការបើកប្រាក់សោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈប្រចាំខែ ជាសមត្ថកិច្ចរបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន រហូតដល់ពេលបង្កើតបាន បេឡាសោធននិវត្តន៍ និង បាត់បង់សម្បទាវិជ្ជាជីវៈ ។

**មាត្រា១៧:** និវត្តជន និង ជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលបានទទួលប្រាក់សោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈប្រចាំខែកន្លងមក ត្រូវបានគិតបញ្ចូលប្រាក់ឧបត្ថម្ភ ប្រពន្ធ កូន ដូចមានចែងក្នុងមាត្រា៨នៃអនុក្រឹត្យនេះ ។

**មាត្រា១៨:** ក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន ត្រូវចេញប្រកាសណែនាំអនុវត្តអនុក្រឹត្យនេះ ។

# ជំពូកទី ៤
## អវសានប្បញ្ញត្តិ

មាត្រា១៩: សហរដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និង គ្រប់ក្រសួងស្ថាប័ន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

អ៊ុង ហួត ហ៊ុន សែន

**កន្លែងទទួល:**
- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ នាយករដ្ឋមន្ត្រីទាំង ២
- គ្រប់ក្រសួង ស្ថាប័ន
- ឯ ក សា រ - កាលប្បវត្តិ

បានជំរាបជូន

នាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២

ស៊ុយ សែម

រដ្ឋលេខាធិការក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...០៥.សរ....

ជាតិ សាសនា ព្រះមហាក្សត្រ

# សារាចរ
## ស្តីពី
## ការកែសម្រួលនីតិវិធីនៃការដាក់មន្ត្រីរាជការស៊ីវិលឱ្យចូលនិវត្តន៍

យោងមាត្រា៥៥ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ បទប្បញ្ញត្តិនៃលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌនីមួយៗដែលពាក់ព័ន្ធនឹងការដាក់មន្ត្រីរាជការស៊ីវិលឱ្យចូលនិវត្តន៍ និងអនុក្រឹត្យលេខ៨០ អនក្រ.បក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០២ ស្តីពីការគ្រប់គ្រងដំណើរការនៃការដាក់មន្ត្រីរាជការស៊ីវិលឱ្យចូលនិវត្តន៍តាមអាយុតាមប្រព័ន្ធព័ត៌មានវិទ្យា ដើម្បីការពារផលប្រយោជន៍ដល់និវត្តជននិងលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងការដាក់មន្ត្រីរាជការស៊ីវិលឱ្យចូលនិវត្តន៍ រាជរដ្ឋាភិបាល ដាក់ចេញនូវវិធានការដូចខាងក្រោម៖

១- ការបោះពុម្ពសលាកបត្រព័ត៌មានមន្ត្រីរាជការស៊ីវិលចូលនិវត្តន៍

- ក្រសួងមុខងារសាធារណៈ ត្រូវបោះពុម្ពសលាកបត្រព័ត៌មានមន្ត្រីរាជការស៊ីវិលចូលនិវត្តន៍សម្រាប់មន្ត្រីរាជការស៊ីវិលដែលដល់អាយុចូលនិវត្តន៍ម្នាក់ៗនៅតាមក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដោយត្រូវមានជាចាំបាច់នូវព័ត៌មានផ្ទាល់ខ្លួនរបស់សាមីជន ស្ថានភាពគ្រួសារ កាលបរិច្ឆេទចូលនិវត្តន៍ អតីតភាពការងារ បៀវត្សចុងក្រោយ ប្រាក់ឧបត្ថម្ភលើកដំបូងម្តងគត់មុនពេលចូលនិវត្តន៍ ប្រាក់សោធននិវត្តន៍ និងលេខគណនីបៀវត្សមន្ត្រីរាជការស៊ីវិលតាមធនាគារ
- ក្រសួងមុខងារសាធារណៈ ត្រូវផ្តល់សលាកបត្រខាងលើជូនដល់គ្រប់ក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិផ្អែកលើករណីពាក់ព័ន្ធនីមួយៗនិងត្រូវផ្តល់សលាកបត្រទាំងអស់នេះ រួមទាំងទិន្នន័យអេឡិចត្រូនិចដល់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល និង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឱ្យបានយ៉ាងតិចរយៈពេល៤(បួន)ខែ មុនកាលបរិច្ឆេទនៃការចូលនិវត្តន៍របស់មន្ត្រីរាជការស៊ីវិលដែលបម្រើការងារនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- ការបោះពុម្ពសលាកបត្រព័ត៌មានមន្ត្រីរាជការស៊ីវិលចូលនិវត្តន៍ ផ្អែកលើបែបបទនិងនីតិវិធីខាងលើ ត្រូវអនុវត្តក្នុងរយៈពេល៣(បី)ខែ ចាប់ពីសារាចរនេះត្រូវបានដាក់ឱ្យអនុវត្ត។

២- ការផ្ទៀងផ្ទាត់ព័ត៌មានក្នុងសលាកបត្រព័ត៌មានមន្ត្រីរាជការស៊ីវិលចូលនិវត្តន៍

- នាយកដ្ឋានបុគ្គលិកឬអង្គភាពគ្រប់គ្រងបុគ្គលិកនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ត្រូវចាត់ចែងឱ្យមន្ត្រីរាជការស៊ីវិលម្នាក់ៗដែលត្រូវដាក់ឱ្យចូលនិវត្តន៍ ពិនិត្យនិងផ្ទៀងផ្ទាត់ព័ត៌មានក្នុងសលាកបត្រព័ត៌មានខាងលើនេះ ហើយត្រូវស្នើសុំការកែតម្រូវក្នុងករណីមានកំហុសឆ្គងក្នុងរយៈពេលយ៉ាងយូរ១(មួយ)ខែ បន្ទាប់ពីទទួលបានសលាកបត្រព័ត៌មានមន្ត្រីរាជការស៊ីវិលចូលនិវត្តន៍
- ក្រសួងមុខងារសាធារណៈ ត្រូវពិនិត្យនិងដោះស្រាយចំពោះសំណើសុំកែតម្រូវសលាកបត្រព័ត៌មានមន្ត្រីរាជការស៊ីវិលចូលនិវត្តន៍យ៉ាងយូរ១(មួយ)ខែ បន្ទាប់ពីទទួលបានសំណើពីក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ

- ក្នុងករណីពុំមានសំណើសុំកែតម្រូវពីក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ក្នុងរយៈពេលកំណត់ខាងលើឬសំណើកែតម្រូវត្រូវបានដោះស្រាយរួចហើយ ព័ត៌មានរបស់មន្ត្រីរាជការស៊ីវិលដែលមាននៅក្នុងសលាកបត្រនឹងត្រូវប្រើប្រាស់ជាមូលដ្ឋានសម្រាប់ដំណើរការនៃការដាក់មន្ត្រីរាជការស៊ីវិលឱ្យចូលនិវត្តន៍ ការបើកផ្តល់ប្រាក់ឧបត្ថម្ភលើកដំបូងម្តងគត់មុនពេលចូលនិវត្តន៍ និងប្រាក់សោធននិវត្តន៍។

៣- ការបើកផ្តល់ប្រាក់ឧបត្ថម្ភលើកដំបូងម្តងគត់មុនពេលចូលនិវត្តន៍

- ក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ត្រូវទទួលខុសត្រូវរៀបចំបែបបទក្នុងការបើកផ្តល់ប្រាក់ឧបត្ថម្ភលើកដំបូងម្តងគត់មុនពេលចូលនិវត្តន៍ ជូនមន្ត្រីរាជការស៊ីវិលតាមរយៈគណនីបៀវត្សប្រចាំខែរបស់សាមីជន ត្រឹមខែចុងក្រោយមុនកាលបរិច្ឆេទកំណត់ការចូលនិវត្តន៍។

៤- ការរៀបចំការដាក់មន្ត្រីរាជការស៊ីវិលឱ្យចូលនិវត្តន៍

- ក្រសួងមុខងារសាធារណៈ ត្រូវរៀបចំសំណើដាក់ជូនរាជរដ្ឋាភិបាល ដើម្បីពិនិត្យនិងសម្រេចការដាក់មន្ត្រីរាជការស៊ីវិលរបស់ក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ឱ្យចូលនិវត្តន៍តាមរយៈអនុក្រឹត្យឬព្រះរាជក្រឹត្យ ផ្អែកតាមករណីនីមួយៗយ៉ាងយូរ ២(ពីរ)ខែ មុនកាលបរិច្ឆេទកំណត់ការចូលនិវត្តន៍របស់មន្ត្រីរាជការស៊ីវិលម្នាក់ៗ
- ក្រសួង ស្ថាប័ន ត្រូវសម្រេចដាក់មន្ត្រីរាជការស៊ីវិលឱ្យចូលនិវត្តន៍តាមប្រកាស សម្រាប់មន្ត្រីរាជការស៊ីវិលស្ថិតក្នុងឋានន្តរស័ក្តិនិងប្រភេទក្របខណ្ឌដែលមានកំណត់ក្នុងលក្ខន្តិកៈដោយឡែក យ៉ាងយូរ ២(ពីរ)ខែ មុនកាលបរិច្ឆេទកំណត់ការចូលនិវត្តន៍របស់មន្ត្រីរាជការស៊ីវិលម្នាក់ៗ
- ក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ មិនអាចបន្តប្រើប្រាស់មន្ត្រីរាជការស៊ីវិលដែលដល់អាយុចូលនិវត្តន៍ឱ្យបំពេញកិច្ចការជាផ្លូវការក្នុងមុខងារសាធារណៈបានឡើយ ព្រមទាំងត្រូវចាត់ចែងដើម្បីធានាឱ្យបាននូវនិរន្តរភាពនៃការងារ។

៥- ការគ្រប់គ្រងនិវត្តជនដោយបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល

- បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិលនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវប្រើប្រាស់សលាកបត្រព័ត៌មានមន្ត្រីរាជការស៊ីវិលចូលនិវត្តន៍ដែលបោះពុម្ពដោយក្រសួងមុខងារសាធារណៈ ដើម្បីរៀបចំធ្វើបច្ចុប្បន្នភាពនិវត្តជនតាមប្រព័ន្ធព័ត៌មានវិទ្យា ផ្តល់សៀវភៅគណនីធនាគារ និងផ្តល់លិខិតទទួលស្គាល់និវត្តជនម្នាក់ៗយ៉ាងយូរឱ្យបាន១(មួយ)ខែ មុនកាលបរិច្ឆេទកំណត់ឱ្យចូលនិវត្តន៍
- ដើម្បីទទួលបានប្រាក់សោធននិវត្តន៍នៅខែបន្ទាប់ ក្រោយពីត្រូវបានផ្តាច់បៀវត្សពីតារាងទូទាត់បៀវត្សរបស់ក្រសួងមុខងារសាធារណៈ មន្ត្រីរាជការស៊ីវិលដែលត្រូវចូលនិវត្តន៍ ត្រូវមកបង្ហាញខ្លួនដើម្បីធ្វើបច្ចុប្បន្នភាពដោយការថតរូបនិងយកស្នាមមេដៃរបស់សាមីជននៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ឬការិយាល័យបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិលរាជធានី ខេត្តក្នុងរយៈពេលយ៉ាងយូរ១(មួយ)ខែមុនកាលបរិច្ឆេទកំណត់ឱ្យចូលនិវត្តន៍។ ក្នុងករណីខកខានរបស់សាមីជន ប្រាក់សោធននិវត្តន៍ មិនទាន់អាចបើកផ្តល់ ជូនសាមីជនបានឡើយ
- ចំពោះនិវត្តជនដែលមិនទាន់ទទួលបានប្រាក់សោធននិវត្តន៍ បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ត្រូវជូនដំណឹងដល់និវត្តជនទាំងអស់ដើម្បីធ្វើបច្ចុប្បន្នភាពដោយការថតរូបនិងយក

ស្នាមមេដៃរបស់សាមីជននៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ឬការិយាល័យបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិលរាជធានី ខេត្ត ក្នុងរយៈពេលយ៉ាងយូរ២ (ពីរ) សប្តាហ៍ បន្ទាប់ពីសារាចរនេះត្រូវបានដាក់ឱ្យអនុវត្ត ដើម្បីធានាការបើកផ្តល់ប្រាក់សោធននិវត្តន៍ជូននិវត្តជនឱ្យបានឆាប់រហ័សបំផុត

- បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិលនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវធ្វើការពិនិត្យ ផ្ទៀងផ្ទាត់ និងធ្វើបច្ចុប្បន្នភាពស្ថានភាពនៃនិវត្តជនម្នាក់ៗ ឱ្យបានទៀងទាត់ និងជាប្រចាំនៅរៀងរាល់ឆ្នាំ។

៦- ការពង្រឹងកិច្ចសហការរវាងក្រសួង ស្ថាប័ន ក្នុងការផ្តល់ទិន្នន័យ

- ក្រសួងមុខងារសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិលនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវសហការផ្តល់ទិន្នន័យដែលពាក់ព័ន្ធនឹងដំណើរការនៃការដាក់មន្ត្រីរាជការស៊ីវិលឱ្យចូលនិវត្តន៍និងការគ្រប់គ្រងស្ថានភាពនិវត្តជន ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តនីតិវិធីដាក់មន្ត្រីរាជការស៊ីវិលឱ្យចូលនិវត្តន៍និងការការពារផលប្រយោជន៍ជូននិវត្តជន។

ទទួលបានសារាចរនេះ ក្រសួងមុខងារសាធារណៈ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ សាលារាជធានី ខេត្ត មន្ទីរនិងអង្គភាពជំនាញរាជធានី ខេត្ត ត្រូវផ្សព្វផ្សាយនិងអនុវត្តឱ្យមានប្រសិទ្ធភាពនិងដោយស្មារតីទទួលខុសត្រូវខ្ពស់ ហើយរាយការណ៍អំពីលទ្ធផលនៃការអនុវត្តមករាជរដ្ឋាភិបាលវិញ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ សីហា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល** :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់សាលារាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# សលាកបត្រមន្ត្រីរាជការស៊ីវិលចូលនិវត្តន៍ឆ្នាំ ២០១៦

## ថ្នាក់កណ្តាល

## អប់រំ យុវជន និង កីឡា

### ១. ព័ត៌មានផ្ទាល់ខ្លួន

| អត្តលេខ | ឈ្មោះខ្មែរ | ឈ្មោះឡាតាំង | ភេទ | ថ្ងៃខែឆ្នាំកំណើត | ទីកន្លែងកំណើត | អាសយដ្ឋានបច្ចុប្បន្ន |
|---|---|---|---|---|---|---|
| 1561200168 | ប៉ុល សុរិទ្ធ | POL SORITH | ប្រុស | 30/11/1956 | សង្កាត់លេខ ៥ ភ្នំពេញ | តាខ្មៅ តាខ្មៅ កណ្តាល |

### ២. ស្ថានភាពគ្រួសារ

**គ្រួសារ**

| | |
|---|---|
| ឈ្មោះប្តី/ប្រពន្ធ | សៅ សុមន្តា |
| ស្លាប់/រស់ | នៅរស់ |
| ថ្ងៃខែឆ្នាំកំណើត | 08/09/1963 |
| មុខរបរ | គ្រូបង្រៀន |

**កូនទទួលប្រាក់ឧបត្ថម្ភ**

| ល.រ | ឈ្មោះ | ភេទ | ថ្ងៃខែឆ្នាំកំណើត |
|---|---|---|---|
| 1 | សុរិទ្ធ មុនីតា | ប្រុស | 20/04/1996 |
| 2 | សុរិទ្ធ វឌ្ឍនា | ប្រុស | 12/07/1994 |

### ៣. ប្រវត្តិការងារ

| ថ្ងៃខែឆ្នាំចាប់ផ្តើមបម្រើការងារ | ថ្ងៃខែឆ្នាំចូលនិវត្តន៍ | រយៈពេលព្យួរការងារ | អតីតភាពការងារ | ភាគរយអតីតភាពការងារ |
|---|---|---|---|---|
| 20/04/1979 | 01/12/2016 | | | |

### ៤. ការងារបច្ចុប្បន្ន

| ក្របខណ្ឌ | មុខតំណែង | បៀវត្សមូលដ្ឋាន | ប្រាក់បំណាច់ | តំបន់ | បង្គ្រប់ | កូន | សហព័ទ្ធ |
|---|---|---|---|---|---|---|---|
| ក.១.៦ | អធិការមធ្យមសិក្សា | 700,720 | 400,000 | | | 10,000 | |

### ៥. ប្រាក់ឧបត្ថម្ភលើកដំបូង ប្រាក់សោធនប្រចាំខែ និងព័ត៌មានធនាគារ

| | | | |
|---|---|---|---|
| ប្រាក់ឧបត្ថម្ភលើកដំបូងម្តងគត់ | | | |
| ប្រាក់សោធនសុទ្ធសាធ | | | |
| ប្រាក់បន្ថែមឲ្យស្មើសោធនអប្បបរមា | | | |
| ប្រាក់ឧបត្ថម្ភសហព័ន្ធ | | | |
| ប្រាក់ឧបត្ថម្ភកូន | | | |
| ប្រាក់សោធនសរុបប្រចាំខែ | | | |
| ធនាគារឈ្មោះ | | លេខគណនីបៀវត្ស | |

*ក្រោយពីបានទទួលសលាកបត្រនេះ សាមីខ្លួនត្រូវទៅបង្ហាញខ្លួនដើម្បីធ្វើបច្ចុប្បន្នភាពនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ឬការិយាល័យបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិលរាជធានី ខេត្ត ក្នុងរយៈពេលយ៉ាងយូរ១(មួយ)ខែមុនកាលបរិច្ឆេទកំណត់អោយចូលនិវត្តន៍។